# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ

## ក្រោមប្រធានបទ ការព្យាបាលរោគផ្លូវចិត្ត (ត)

website ៖ www.hoksavann.org

ថ្ងៃទី១៣ មីនា ២០០៩



### ព្រះសង្ឃអប់រំអ្នកមានវិបត្តិផ្លូវចិត្ត

តាមទំនៀមទំលាប់ខ្មែរ ពេលមានសមាជិកគ្រួសាររបស់ខ្លួនមានវិបត្តិផ្លូវចិត្តតែងនាំទៅវត្ត ដើម្បីឲ្យព្រះសង្ឃជួយដោះស្រាយ ។ ព្រះសង្ឃគប្បីជួយដោះស្រាយដោយសួរដំណើរហេតុដែលនាំឲ្យមានវិបត្តិផ្លូវចិត្តនេះ ហើយដោះស្រាយទៅតាមហេតុដែលនាំឲ្យខូចផ្លូវចិត្ត ។ ដំណោះស្រាយគ្មានអ្វីក្រៅពីការពន្យល់ធម៌អាថ៌ឲ្យឃើញហេតុដែលនាំឲ្យកើតទុក្ខផ្លូវចិត្ត ។ របស់បាត់ រកស៊ីខាត ប្រឡងធ្លាក់ជាដើម ត្រូវខំព្យាយាមជាថ្មី បើព្យាយាមបានសំរេចដូចបំណង ការទោមនស្សតូចចិត្តក៏ត្រូវរលត់ ការរីករាយចិត្តក៏កើតឡើង ។ បើមិនសំរេចដូចបំណង ចិត្តនៅតែកើតទុក្ខដដែល ដូចនេះត្រូវប្រើវិធីទីពីរ គឺការលះបង់ឈប់គិតឈប់ស្ដាយ ដោយពិចារណាឲ្យឃើញការពិតថា របស់អ្វីទាំងអស់តែងតែប្រែប្រួលផ្លាស់ប្ដូរ មិនទៀងទាត់ កាលណាពិចារណាឃើញការពិតនេះហើយ ការទោមនស្សតូចចិត្តក៏ត្រូវរលត់ ។ ព្រឹត្តិការណ៍ខ្លះមានទម្ងន់ខ្លាំង ដូចជាមានសមាជិកគ្រួសារណាម្នាក់បានត្រូវស្លាប់ បើមិនយកផ្លូវធម៌មកពិចារណាឲ្យឃើញការពិតទេ មានបុគ្គលខ្លះសោកស្ដាយខ្លាំងរហូតដល់វង្វេងស្មារតី ។ សេចក្ដីទុក្ខនេះ កើតពីការបាត់បង់ជនជាទីស្រឡាញ់ ដែលបាត់បង់ជីវិតទៅ ។ ដូច្នេះព្រះសង្ឃមានភារកិច្ចជួយណែនាំពន្យល់ឲ្យលះបង់នូវជនជាទីស្រឡាញ់ ដែលមិនអាចរស់ឡើងវិញបាន

ដោយពន្យល់បន្ថែមអំពីកម្មផលរបស់មនុស្សសត្វ ដែលតែងតែប្រព្រឹត្តទៅតាមអំពើរបស់ខ្លួន (កម្មុនា វត្តកី លោកា) ។

ការគ្រាន់តែសូត្រមន្ត ស្រោចទឹក ដាក់ខ្សែកថា កន្សែងយន្ត ពុំមែនជាមធ្យោបាយធ្វើឲ្យអ្នកមានវិបត្តិផ្លូវចិត្តបានសះស្បើយឡើយ ។ វិធីនេះគ្រាន់តែជាការលើកទឹកចិត្តបានខ្លះ ប៉ុន្តែមិនអាចបំបាត់ហេតុដែលនាំឲ្យកើតទុក្ខ ។ ដូចក្នុងអរិយសច្ច៤ ទុក្ខសច្ចសេចក្តីទុក្ខកើតពីការកើតឡើងនៃខន្ធ៥មានរូបខន្ធជាដើម មានមូលហេតុពីអវិជ្ជា តណ្ហា ឧបាទាន និងកម្ម ។ យ៉ាងណាមិញ អ្នកកើតទុក្ខផ្លូវចិត្តខ្លះ កើតអំពីការបាត់បង់ជនជាទីស្រឡាញ់ ។ ដើម្បីរំលត់ទុក្ខនេះ ត្រូវដកចិត្តចេញពីការស្រឡាញ់ សេចក្តីទុក្ខក៏ត្រូវរលត់ ។ ចំណែកកន្សែងយន្ត ទឹកមន្តជាដើម មិនអាចធ្វើឲ្យទុក្ខរលត់បានឡើយ ព្រោះពុំមែនជាវិធីដោះស្រាយត្រូវតាមហេតុដែលនាំឲ្យកើតទុក្ខ ។ ព្រះសង្ឃគប្បីពន្យល់ឲ្យឃើញហេតុផលថា ការយំសោកយ៉ាងណា ក៏ជនដែលស្លាប់បាត់ជីវិតទៅហើយ មិនអាចរស់ឡើងវិញឡើយ ដូច្នេះការយំសោកនោះជាការឥតប្រយោជន៍ នាំឲ្យខូចផ្លូវចិត្តវិញទេ ត្រូវតែតាំងស្មារតីឲ្យរឹងប៉ឹងបន្តជីវិតរបស់ខ្លួនតទៅទៀត ដោយពិចារណាឃើញភាពគ្មានខ្លឹមសារនៃសង្ខារទាំងឡាយរួមទាំងខ្លួនអ្នកមានវិបត្តិផ្លូវចិត្តផង ។

តាមការសង្កេត ព្រះសកម្មភាពរបស់ព្រះពុទ្ធក្នុងការជួយរំដោះទុក្ខមនុស្សសត្វ ដោយវិធីសំដែងធម៌ទេសនា បង្ហាញផ្លូវប្រតិបត្តិ ដូចព្រះអង្គបង្ហាញមគ្គប្រកបដោយអង្គ៨ ថាជាផ្លូវប្រតិបត្តិទៅកាន់ការរំលត់ទុក្ខ មានជាតិទុក្ខជាដើម ពុំមែនព្រះអង្គប្រទានទឹកមន្ត ខ្សែកថា កន្សែងយន្ត ជាវិធីរំលត់ទុក្ខឡើយ ។ ក្រោយពេលត្រាស់ដឹង ព្រះអង្គបានព្យាយាមសំដែងធម៌ទេសនាប្រោសសត្វគ្រប់ឋានៈ ស្តេច សេដ្ឋី គហបតី អ្នកមានអំណាច អ្នកមានទ្រព្យសម្បត្តិ ឲ្យមានធម៌ក្នុងខ្លួន យកអំណាចយកទ្រព្យសម្បត្តិរបស់ខ្លួនទៅបំរើសង្គម ។ ពេលនាងបដាចាមកថ្វាយបង្គំព្រះពុទ្ធ ព្រះអង្គសំដែងធម៌ទេសនា ប្រោសឲ្យនាងដកចិត្តចេញពីជនជាទីស្រឡាញ់របស់នាងដែលស្លាប់បាត់បង់ជីវិតទៅ មិនឃើញព្រះអង្គប្រទានទឹកមន្ត ដើម្បីឲ្យនាងបាត់កើតទុក្ខឡើយ ។ មួយទៀត ពេលដែលនាងកីសាគោតមី ដែលកើតទុក្ខខ្លាំងរហូតដល់វង្វេងស្មារតី ខំបីកូនដែលស្លាប់ដើររកព្រះពុទ្ធឲ្យជួយកូននាងឲ្យរស់ឡើងវិញ ព្រះអង្គឲ្យនាងពិសោធដោយ

ខ្លួនឯង ដោយឲ្យរកគ្រាប់ស្ពៃចំពោះផ្ទះណាដែលមិនមានមនុស្សស្លាប់ ។ ទីបំផុតទើបនាងមានស្មារតីឡើងវិញដឹងច្បាស់ថា ទីណាក៏មានមនុស្សស្លាប់ដែរ ។ ត្រង់នេះបញ្ជាក់ថា ការសោយសោករបស់នាងបានត្រូវរលត់ដោយសារធម៌ទេសនារបស់ព្រះអង្គ ពុំឃើញព្រះអង្គសូត្រធម៌ស្រោចទឹកឲ្យនាងបាត់កើតទុក្ខឡើយ ។ ដើម្បីជាការសម្របសម្រួលតាមទំនៀមទំលាប់ផង តាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធផង ព្រះសង្ឃអ្នកអប់រំចំពោះអ្នកមានវិបត្តិផ្លូវចិត្ត គួរពន្យល់ដូចន័យ ដែលបានពោលមកខាងលើនេះ ជាមួយគ្នានឹងការសូត្រធម៌ជូនពរលើកកម្លាំងផ្លូវចិត្តផង ។

(នៅមានត)